# ភៃសជ្យគុរុ និងការព្យាបាលសម័យបុរាណ

***តើអ្វីទៅជាភៃសជ្យគុរុ?*** បើយើងពិនិត្យមើលលើពាក្យភៃសជ្យគុរុ គឺជាការផ្សំរវាងពាក្យ២ព្យាង្គ គឺ ***ភៃសជ្យ=ភេសជ្ជ*** ដែលមានន័យថាថ្នាំឬឱសថ រីឯ ***គុរុ*** មានន័យថា គ្រូ រឺអ្នកជំនាញខាងអ្វីមួយ ដូចនេះវាមានន័យថា គ្រូនៃថ្នាំ ឬគ្រូនៃស្តេចថ្នាំ។ តាមការពន្យល់របស់លោកស្រី ពៅ សាវរស់ ភៃសជ្យគុរុគឺជាគ្រូចាត់ចែងថ្នាំ។[១] ការបង្ហាញអំពីភៃសជ្យគុរុដំបូងគឺក្នុងគម្ពីរមហាយាន ហៅថា ***ភៃសជ្យគុរុវៃទុរ្យប្រភរាជសូត្រ*** (Bhaiṣajyaguruvaiḍuryaprabharaja Sutra) *ហើយកាន់តែសមញ្ញក្នុងគម្ពីព្រះពុទ្ធជាគ្រូថ្នាំ* (Medecine Buddha Sutra)។ *គម្ពីរសំស្រ្កឹតដែលមានអាយុកាលមុនសតវត្សទី៧ និយាយអំពីសូត្រនេះ រកឃើញនៅ* Bamiyan (Afghanistan) *និង* Gilgit (Pakistan) *ដែលតំបន់ទាំង២នេះជាផ្នែកនៃអាណាចក្រពុទ្ធសាសនារបស់ គន្ធរ* (Gandhara)។[២]

*ក្នុងសង្គមខ្មែរសម័យអង្គរ តាមសិលាចារឹកមួយចំនួន ពាក្យភៃសជ្យគុរុ មានបង្ហាញតែក្នុងសិលាចារឹកសតវត្សទី១៣ប៉ុណ្ណោះ។ ឧទាហរណ៍ ក្នុងសិលាចារឹក* K.453[៣] *បង្ហាញពីឈ្មោះទេពមួយ ហៅថា* ***វ្រះ រាជ្យឝ្រី ភៃសជ្យគុរុ*** (*ព្រះ រាជ្យស្រី ភៃសជ្យគុរុ*)។ *និយាយអោយចំទៅ ពាក្យឬទេពភៃសជ្យគុរុនេះមានបង្ហាញតែក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧* (*១១៨១គ.សដល់១២២០គ.ស*) *ពិសេសតាមសិលាចារឹក និងប្រាសាទរបស់ព្រះអង្គ។ ជាក់ស្តែងដូចជា សិលាចារឹកប្រាសាទបាយ័ន្ត* (K.293)[៤] *និងសិលាចារឹកសៃហ្វុង* (K.368)[៥] *ជាដើម។*

*បើយើងពិនិត្យមើលក្នុងប្រវត្តិសាស្រ្ត និងប្រវត្តិសិល្បៈខ្មែរ ភៃសជ្យគុរុហាក់ពុំមានវត្តមានក្នុងសម័យមុនអង្គរ ឬសម័យក្រោយអង្គរទេ។ លិទ្ធិ ឬទម្រង់នៃការគោរពលើភៃសជ្យគុរុហាក់លេចមានឡើងក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២* (*១១១៣គ.សដល់១១៥០គ.ស*) *ឬរចនាបថអង្គរវត្តក្នុងទម្រង់ជាព្រះពុទ្ធទ្រង់គ្រឿង សម្លូរដោយគ្រឿងអលង្កា ជួនកាល*

---

[១] Savaros Pou 1992:357
[២] https://www.learnreligions.com/bhaisajyaguru-the-medicine-buddha-449982
[៣] G. Cœdès 1951:117
[៤] Robert Dalet 1935:187
[៥] Louis Finot 1903:18-33

*អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា*

គង់លើបល្ល័ង្កនាគ ជួនកាលលើបល្ល័ង្កធម្មតា (រូបលេខ១)[៦]។ ក្រោយមក លទ្ធិនេះបានរីកចម្រើន និងពេញនិយមក្នុងព្រះបាទជ័យវរ្ម័នទី៧ ឬសម័យបាយ័ន្ត។ សិលាចារិក K.453 នៅភូមិមោង[៧] បង្ហាញពីការស្ថាបនាបដិមាបែបពុទ្ធសាសនាមហាយានយ៉ាងច្រើនដោយក្សត្រមួយអង្គ ប្រហែលជាព្រះបាទជ័យវរ្ម័នទី៧ ក្នុងឆ្នាំ១២០៦គ.ស ក្នុងនោះមានបដិមាមួយជាទេពឈ្មោះ***ព្រះ ពេជ្យគ្រូ ភៃសជ្យគុរុ***។ ប៉ុន្តែ តាមរយៈបដិមាធ្វើអំពីសំរឹទ្ធខ្លះត្រូវបានគេគិតថាស្ថិតនៅក្នុងរចនាបថអង្គរវត្ត សតវត្សទី១២ (រូបលេខ២)[៨]។

ក្នុងបរិបទនេះ បដិមាឬទេពភៃសជ្យ ដែលបង្កើតឡើងដោយ ព្រះបាទជ័យវរ្ម័នទី៧ គឺជាទេពតំណាងអោយការសង្គ្រោះតាមរយៈការព្យាបាលដោយការប្រើឱសថ ថ្នាំ រុក្ខជាតិផ្សេងៗ។ ទេពភៃសជ្យគុរុ គឺជាបដិមាតំណាងដោយព្រះពុទ្ធមួយបែប ជាទូទៅបង្ហាញតាមរយៈបដិមាជាព្រះពុទ្ធទ្រង់ភ្នែន ក្នុងកាយវិការសមាធិ ពិសេសនោះគឺមានទ្រវត្ថុម៉្យាងនៅលើបាតដៃ បដិមាខ្លះមានគ្រាប់មូលទ្រវែងមួយរាងដូចផ្លែស្រម៉ (រូបលេខ៣[៩]) និងភាគច្រើនមានរាងជាដន្ទាប់ឬភាជន៍ម៉្យាង (រូបលេខ៤[១០]) ដែលអ្នកស្រាវជ្រាវបានសន្និដ្ឋានខុសគ្នាទៅលើវត្ថុនោះ។

បដិមាភៃសជ្យគុរុ និងបដិមាដទៃទៀតចំនួន ៧៩៨ ត្រូវបានគេស្ថាបនាឡើងតម្កល់ក្នុងហោបន់ស្រន់របស់មន្ទីរពេទ្យនានាដែលព្រះបាទជ័យវរ្ម័នទី៧បានកសាងពាសពេញអាណាចក្ររបស់ព្រះអង្គ។ តាមសិលាចារិកប្រាសាទតាព្រហ្ម K.273[១១] បង្ហាញថាព្រះអង្គបានអោយគេស្ថាបនាមន្ទីរពេទ្យ (អរោគសាលា) ចំនួន១០២ សម្រាប់តម្រូវការលើការព្យាបាលប្រជានុរាស្ត្រ។

ក្នុងលក្ខណៈសិល្បៈខ្មែរ ភៃសជ្យគុរុត្រូវបានបង្ហាញជា៣ទម្រង់ (១)បដិមាព្រះពុទ្ធទ្រង់ភ្នែនទោល (រចនាបថអង្គរវត្ត និងបាយ័ន្ត) និង(២)បដិមាព្រះពុទ្ធទ្រង់ភ្នែនអមដោយពោធិសត្វ២អង្គ (រូបលេខ៥[១២]) គឺលោកេស្វរៈឈរនៅខាងស្តាំ និងប្រាជ្ញាបារមីតាឈរនៅ

---

៦ Emma C. Bunker and Douglas Latchford 2004:266

៧ E. Lunet de Lajonquière 1911:338

៨ Sherman E. Lee 1969:66

៩ https://collection.efeo.fr/ws/web/app/collection/record/250373

១០ Marlene L. Zefferys et al., 2001:82

១១ G. Cœdès 1906:80

១២ Emma C. Bunker and Douglas Latchford 2004:51

ខាងឆ្វេង (៣)ចម្លាក់លើថ្មមួយផ្ទាំង ជាក្បាច់ក្រឡោតខ្ពស់ មានរូបព្រះពុទ្ធទ្រង់ក្អែនលើបល្ល័ង្គនាគ ខាងស្តាំជាលោកេស្វរៈឈរ និងខាងឆ្វេងជាប្រាជ្ញាបារមីតាឈរ (រូបលេខ៦)។ ទម្រង់ទី២ និងទី៣ មានតែក្នុងសម័យបាយ័ន្ត ពិសេសចម្លាក់ក្រឡោតខ្ពស់ និងបដិមាធ្វើពីលោហៈផ្សេងៗ។

## អំពីការព្យាបាលជំងឺសម័យបុរាណ

តាមការស្រាវជ្រាវ គេរកឃើញថា ការព្យាបាលជំងឺត្រូវបានគេប្រើប្រាស់រុក្ខជាតិផ្សេងៗ។ ប៉ុន្តែ ពុំមានការសិក្សាស្រាវជ្រាវលម្អិតអំពីប្រភេទរុក្ខជាតិជាឱសថទាំងនោះទេ។ យើងមិនអាចដឹងអំពីប្រភេទថ្នាំ ការធ្វើ និងការផ្សំសម្រាប់ព្យាបាលជំងឺផ្សេងទេ។ ការសិក្សាដ៏កម្រិបែបនេះ គឺមានសារសំខាន់លើការសិក្សាបែបជាតិពន្ធុវិទ្យា ឬនរវិទ្យាបែបវេជ្ជសាស្ត្រ។[១៣] លោក Rethy K. Chhem បានសិក្សាលើទ្រឹស្តីនានអំពីថ្នាំបុរាណខ្មែរ និងឥទ្ធិពលរបស់ទ្រឹស្តីទាំងនោះទៅលើការចាត់ថ្នាក់នៃប្រភេទជំងឺផ្សេងៗ ពិសេសការច្របាច់បញ្ចូលគ្នានៃទ្រឹស្តីខាងវិជ្ជាពេទ្យដែលបានមកពីឥណ្ឌា (ទ្រឹស្តីអាយុវេទ៌ និងទ្រឹស្តីព្រះពុទ្ធសាសនា) និងចិន រួមបញ្ចូលជាមួយគំនិតរបស់ខ្មែរអំពីវិធីព្យាបាលរោគ។[១៤] យើងអាចសិក្សាបានអំពីការព្យាបាលបែបបុរាណក្នុងពេលបច្ចុប្បន្ន ដែលអាចជាគំរូ ឬប្រពៃណីបន្តមកតាំងពីសម័យបុរាណ គ្រាន់តែថា វាខុសគ្នាបន្តិចបន្តួចពីតំបន់១ទៅតំបន់មួយ និងការប្រើ ការផ្សំឱសថប៉ុណ្ណោះ។ ចម្លាក់មួយចំនួនលើជញ្ជាំងថែវខាងត្បូង ស្ទាបខាងកើតរបស់ប្រាសាទបាយ័ន (រូបលេខ៧-១០) បង្ហាញពីកន្លែងព្យាបាលមនុស្សដែលមានជំងឺដោយមានការបុក ឬដាំថ្នាំសម្រាប់ប្រើប្រាស់ក្នុងការព្យាបាលជំងឺ។

---

[១៣] Chulean. Ang 1992:101-114
[១៤] Rethy K. Chhem 2001:1-15

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២១



រូបលេខ២២



រូបលេខ២៣



រូបលេខ២៤



រូបលេខ២៥



រូបលេខ២៦



រូបលេខ៧



រូបលេខ៨



រូបលេខ៩



រូបលេខ១០

## ឯកសារយោង


Chulean. Ang, (1992), *Apports indiens à la médecine traditionnelle khmère. Considérations préliminaires* , Journal of the European Ayurvedic Society, Reinbeik, vol. 2.

E. Lunet de Lajonquière (1911). *Inventaire Descriptif des Monuments du Cambdoge*, Tome III, PEFEO, Paris. Emma C. Bunker and Douglas Latchford, (2004), *Adoration and Glory-The Golden Age of Khmer Art*, Art Media Resources, Chicago.

https://www.learnreligions.com/bhaisajyaguru-the-medicine-buddha-449982

https://collection.efeo.fr/ws/web/app/collection/record/250373

G. Cœdès (1906), *La Stèle de Ta-Prohm*, BEFEO, Volume VI, Paris, pp44-81.

G. Cœdès (1951), *Inscription du Cambodge*, Volume III, Paris.

Louis Finot, (1903), *L'Inscription Sanskrite de Sai-Fong*, BEFEO, Tome III, Paris.

Marlene L. Zefferys et al., (2001), Heaven and Empire-Khmer Bronzes from the 9th to the 15th Centuries, White Lotus, Bangkok.

Rethy K. Chhem, (2001), *Les Doctrines médicales Khmères: Nosologie et methods diagnostiques*, Siksācakr, No 3, Phnom Penh.

Robert Dalet, (1935), Le Bayon, BEFEO, Tome XXXV, Paris.

Savaros Pou, (1992), *An Old Khmer-French-English Dictionary*, Cedoreck, Paris.

Sherman E. Lee, (1969), *Ancient Cambodian Sculpture*, London(?).


អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា